# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ: ១២៤/១៥ ក.អ.ជ.ប្រក

ថ្ងៃសុក្រ ៥កើត ខែជេស្ឋ ឆ្នាំមមែ ព.ស.២៥៥៩
រាជធានីភ្នំពេញ ថ្ងៃទី២២ខែឧសភា គ.ស. ២០១៥

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

# ស ម្រេ ច

**ប្រការ ១.-** បញ្ចប់តំណែងថ្នាក់ដឹកនាំ និងមន្ត្រីដែលស្ថិតក្នុងសមាសភាពគណៈកម្មាធិការកំណត់ បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា និងអង្គភាពលទ្ធកម្មសាធារណៈ ប្រចាំក្រសួងអភិវឌ្ឍន៍ជនបទទាំងអស់ ដែលបានទទួលការតែងតាំងមុនថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ ។

**ប្រការ ២.-** តែងតាំងសមាសភាពគណៈកម្មាធិការលទ្ធកម្ម (គល) ប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានរាយនាមដូចខាងក្រោម÷

| | | |
|---|---|---|
| ១- **ឯកឧត្តម ជា សុផារ៉ា** | រដ្ឋមន្ត្រី | ប្រធាន |
| ២- **ឯកឧត្តម ស្ងួស គង់** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- **ឯកឧត្តម ទ្រី មេង** | រដ្ឋលេខាធិការ | សមាជិក |
| ៤- **ឯកឧត្តម អ៊ុន ចន្ថា** | រដ្ឋលេខាធិការ | សមាជិក |
| ៥- **ឯកឧត្តម ហួត សារឹម** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៦- **ឯកឧត្តម ថេង ច័ន្ទសង្វារ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧- **ឯកឧត្តម សាន វិសាល** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨- **ឯកឧត្តម ឱម សំអ៊ើល** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៩- **ឯកឧត្តម ចាន់ ដារ៉ុង** | អគ្គនាយកបច្ចេកទេស | សមាជិក |
| ១០- **លោក គង់ គឿន** | ប្រធាននា. ផ្លូវលំជនបទ | សមាជិក |
| ១១- **លោក ឃាន សុម៉ារ៉ា** | ប្រធាននា. ផ្គត់ផ្គង់ និងហិរញ្ញវត្ថុ | សមាជិក |
| ១២- **លោក ម៉ា សុវណ្ណា** | ប្រធាននា. ផែនការ និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ១៣- **លោក ម៉ឹង សុខលាភ** | ប្រធានអង្គភាពលទ្ធកម្ម | លេខាធិការ |
| ១៤- **លោក លោកស្រី** | តំណាងក្រសួង-ស្ថាប័នអង្គភាពពាក់ព័ន្ធ | សមាជិក |

**ប្រការ ៣.-** តែងតាំងសមាសភាពអង្គភាពលទ្ធកម្ម (អល) ប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានរាយនាមដូចខាងក្រោម÷

| | |
|---|---|
| ១- **លោក ម៉ឹង សុខលាភ** | ប្រធាន |
| ២- **លោក ធួន តារា** | អនុប្រធាន |

៣- កញ្ញា ភាយ សុធាវី អនុប្រធាន
៤- លោក ភា សុធី សមាជិក
៥- លោក ខួន បុណ្ណាមី សមាជិក

**ប្រការ ៤.-** គណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មសាធារណៈរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តតួនាទី និងភារកិច្ច ដូចមានកំណត់ក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១២ អនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ប្រកាសលេខ ៣៨១ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ ៥.-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ អង្គភាពទាំងអស់ក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីជនដូចមានរាយនាមក្នុងប្រការ ២ និងប្រការ៣ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

**ជា សុផារ៉ា**

**<u>កន្លែងទទួល</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ ៦
  *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ



Download